**អ អិម អេ (ខេមបូឌា) ម.ក**

# ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
# សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

**អេ អិម អេ (ខេមបូឌា) ម.ក**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**
**សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤**

| **មាតិកា** | **ទំព័រ** |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២ - ៣ |
| របាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេល | ៤ - ៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ៧ - ៨ |
| កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៩ - ២៨ |
| របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២៩ - ៣០ |

**អ អិម អេ (ខេមបូឌា) ម.ក**

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលនៃ អ អិម អេ (ខេមបូឌា) ម.ក គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ និងព្រមទាំងរបាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេលសម្រាប់ត្រីមាស និងរយៈពេល ៦ខែ របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេលសម្រាប់រយៈពេល ៦ខែដែលបានបញ្ចប់ និងកំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត្រូវបានគេស្គាល់ជារួមថា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល") បានបង្ហាញត្រឹមត្រូវនូវទិដ្ឋភាពជាសារវន្តទាំងអស់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

**ងន សាំង**
**នាយកប្រតិបត្តិ**

ថ្ងៃទី៖ 28 AUG 2024

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
# គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម ពាន់រៀល | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម ពាន់រៀល |
|---|---|---|---|---|---|
| ទ្រព្យសកម្ម | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ២០.៣០៨.៤៣៦ | ៨៣.៤៦៧.៦៧២ | ១៨.៧៦៥.៦៣១ | ៧៦.៦៥៧.៦០៣ |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | | ២៧.៨១៥.៧០១ | ១១៤.៣២២.៥៣១ | ២៦.៧៩៣.៨២២ | ១០៩.៤៥២.៧៦៣ |
| ពន្ធពន្យារទ្រព្យសកម្មសុទ្ធ | | ២.១៥២.៧៧២ | ៨.៨៤៧.៨៩៣ | ២.៤១៨.២៦៧ | ៩.៨៧៨.៦២១ |
| ការវិនិយោគផ្សេងៗ | | ៥.៦០០.០០០ | ២៣.០១៦.០០០ | ៥.៦០០.០០០ | ២២.៨៧៦.០០០ |
| ប្រាក់កក់ | | ៥.៦០០.០០០ | ២៣.០១៦.០០០ | ៥.៦០០.០០០ | ២២.៨៧៦.០០០ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៦១.៤៧៦.៩០៩** | **២៥២.៦៧០.០៩៦** | **៥៩.១៧៧.៧២០** | **២៤១.៧៤០.៩៨៧** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ៦ | ៨២.៤៣៨.៨៧២ | ៣៣៨.៨២៣.៧៦៤ | ១៥៨.០០១.៣៤៤ | ៦៤៥.៤៣៥.៤៩០ |
| គណនីអតិថិជនពាណិជ្ជ និង គណនីត្រូវទទួលផ្សេងៗ | | ២០.២៦៣.៧៥៧ | ៨៣.២៨៤.០៤១ | ២២.២៥៨.៣៥៥ | ៩០.៩២៥.៣៨០ |
| ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ | | ៨.៨៤៥.៣២៥ | ៣៦.៣៥៤.២៨៦ | ៦.០៨៩.៥០១ | ២៤.៨៧៥.៦១២ |
| ប្រាក់បញ្ញើរយៈពេលខ្លី | ៧ | ១០.០០០.០០០ | ៤១.១០០.០០០ | - | - |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨ | ២៨.៣៨៤.០៧៤ | ១១៦.៦៥៨.៥៤៤ | ២២.១៦២.៦០៥ | ៩០.៥៣៤.២៤១ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១៤៩.៩៣២.០២៨** | **៦១៦.២២០.៦៣៥** | **២០៨.៥១១.៨០៥** | **៨៥១.៧៧០.៧២៣** |
| **ទ្រព្យសកម្មសរុប** | | **២១១.៤០៨.៩៣៧** | **៨៦៨.៨៩០.៧៣១** | **២៦៧.៦៨៩.៥២៥** | **១.០៩៣.៥១១.៧១០** |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | | ៤.០០០.០០០ | ១៦.០០០.០០០ | ៤.០០០.០០០ | ១៦.០០០.០០០ |
| ចំណេញរក្សាទុក | | ១២១.២៦០.៣០៥ | ៤៩៤.៥២៦.០៧២ | ១២០.០៨៨.៦០៨ | ៤៨៩.៧៥១.៤០៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៤.២៩៣.៧៨២ | - | ១.១៥០.៥៥៧ |
| **មូលធនសរុប** | | **១២៥.២៦០.៣០៥** | **៥១៤.៨១៩.៨៥៤** | **១២៤.០៨៨.៦០៨** | **៥០៦.៩០១.៩៦៤** |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
# គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | កំណត់ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ឥណទាន និងប្រាក់កម្ចី | ១០ | ២៥.៥០០.០០០ | ១០៤.៨០៥.០០០ | ៣១.៨០៧.៨៣៤ | ១២៩.៩៣៥.០០២ |
| បំណុលភតិសន្យា | | ២៧.៩៤២.៨៥៤ | ១១៤.៨៤៥.១៣០ | ២៦.៧៩៤.០១២ | ១០៩.៤៥៣.៥៣៩ |
| **បំណុលរយៈពេលវែងសរុប** | | **៥៣.៤៤២.៨៥៤** | **២១៩.៦៥០.១៣០** | **៥៨.៦០១.៨៤៦** | **២៣៩.៣៨៨.៥៤១** |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជ និង គណនីត្រូវទូទាត់ផ្សេងៗ | | ១៧.៣៤៥.០៤៧ | ៧១.២៨៨.១៤៣ | ៩.១៨៨.៦៨៣ | ៣៧.៥៣៥.៧៧០ |
| បំណុលកិច្ចសន្យា | ៩ | ៤.៨៣៣.៤៩៦ | ១៩.៨៦៥.៦៦៩ | ៤.៧០៣.៦៩២ | ១៩.២១៤.៥៨២ |
| ទឹកប្រាក់ជំពាក់ទៅភាគីពាក់ព័ន្ធ | | ៦៤៣.៩១១ | ២.៦៤៦.៤៧៤ | ២២.៨២៥.៨១១ | ៩៣.២៤៣.៤៣៨ |
| ឥណទាន និងប្រាក់កម្ចី | ១០ | ៧.៦៣៤.៧៧១ | ៣១.៣៧៨.៩០៩ | ៤៥.៥២៥.៥៧៣ | ១៨៥.៩៧១.៩៦៦ |
| បំណុលភតិសន្យា | | ១.១៥១.៩៤៩ | ៤.៧៣៤.៥១០ | ៨៨៥.២៩៦ | ៣.៦១៦.៤៣៤ |
| បំណុលពន្ធលើប្រាក់ចំណូល | | ១.០៩៦.៦០៤ | ៤.៥០៧.០៤២ | ១.៨៧០.០១៦ | ៧.៦៣៩.០១៥ |
| **បំណុលរយៈពេលខ្លីសរុប** | | **៣២.៧០៥.៧៧៨** | **១៣៤.៤២០.៧៤៧** | **៨៤.៩៩៩.០៧១** | **៣៤៧.២២១.២០៥** |
| **បំណុលសរុប** | | **៨៦.១៤៨.៦៣២** | **៣៥៤.០៧០.៨៧៧** | **១៤៣.៦០០.៩១៧** | **៥៨៦.៦០៩.៧៤៦** |
| **មូលធន និងបំណុលសរុប** | | **២១១.៤០៨.៩៣៧** | **៨៦៨.៨៩០.៧៣១** | **២៦៧.៦៨៩.៥២៥** | **១.០៩៣.៥១១.៧១០** |

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## របាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | | រយៈពេល ៣ខែ បញ្ចប់ | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | |
| | កំណត់ | មិនបានធ្វើសវនកម្ម | | មិនបានធ្វើសវនកម្ម | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូល | ១១ | ១០៨.១៦៨.១១៨ | ៤៤១.៣២៥.៩២១ | ១១៨.២២១.០២៣ | ៤៨៧.០៧០.៦១៥ |
| ថ្លៃដើមនៃការលក់ | | (៩២.៩៥៨.៣០៨) | (៣៧៩.២៦៩.៨៩៧) | (៩៦.៦០៤.៧៦៩) | (៣៩៨.០១១.៦៤៨) |
| **ចំណេញដុល** | | **១៥.២០៩.៨១០** | **៦២.០៥៦.០២៤** | **២១.៦១៦.២៥៤** | **៨៩.០៥៨.៩៦៧** |
| ចំណូលផ្សេងៗ | | ៧៣៨.៤៩៨ | ៣.០១៣.០៧២ | ២១៥.២៨៧ | ៨៨៦.៩៨២ |
| ចំណាយប្រតិបត្តិការ | | (២.៩៤៩.៨១៣) | (១២.០៣៥.២៣៧) | (២.៦៧០.២៩០) | (១១.០០១.៥៩៥) |
| ចំណាយទីផ្សារ | | (១.៦៧៤.៦៣៦) | (៦.៨៣២.៥១៥) | (១.៨៧៥.២៦៤) | (៧.៧២៦.០៨៨) |
| ចំណាយរដ្ឋបាល | | (៣.៦៤៨.៨៩១) | (១៤.៨៨៧.៤៧៥) | (៣.៧០៧.៣៥០) | (១៥.២៧៤.២៨២) |
| **ចំណេញពីប្រតិបត្តិការ** | | **៧.៦៧៤.៩៦៨** | **៣១.៣១៣.៨៦៩** | **១៣.៥៧៨.៦៣៧** | **៥៥.៩៤៣.៩៨៤** |
| ចំណាយហិរញ្ញប្បទាន | | (១.៣៧៣.៤១៨) | (៥.៦០៣.៥៤៥) | (១.៦១២.៦៥៩) | (៦.៦៤៤.១៥៥) |
| **ចំណេញមុនបង់ពន្ធ** | | **៦.៣០១.៥៥០** | **២៥.៧១០.៣២៤** | **១១.៩៦៥.៩៧៨** | **៤៩.២៩៩.៨២៩** |
| ពន្ធលើប្រាក់ចំណូល | ១២ | (១.២៩២.១១៣) | (៥.២៧១.៨២១) | (១.៣៨២.៦១២) | (៥.៦៩៦.៣៦១) |
| **ចំណេញក្នុងគ្រា** | | **៥.០០៩.៤៣៧** | **២០.៤៣៨.៥០៣** | **១០.៥៨៣.៣៦៦** | **៤៣.៦០៣.៤៦៨** |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| *ធាតុដែលអាចមិនត្រូវបានចាត់ថ្នាក់ ឡើងវិញទៅក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៨.៦០៦.៩៤២ | - | ៩.៣៥០.៩២៨ |
| **លទ្ធផលលម្អិតសរុបក្នុងគ្រា** | | **៥.០០៩.៤៣៧** | **២៩.០៤៥.៤៤៥** | **១០.៥៨៣.៣៦៦** | **៥២.៩៥៤.៣៩៦** |

## របាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | |
| | កំណត់ | មិនបានធ្វើសវនកម្ម | | មិនបានធ្វើសវនកម្ម | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូល | ១១ | ២១៤.៣១២.៨៩៩ | ៨៧៣.៣២៥.០៦៣ | ២៧២.៧៧២.៥១៩ | ១.១១៦.៧៣០.៦៩៣ |
| ថ្លៃដើមនៃការលក់ | | (១៨៣.៩១០.៧៣៥) | (៧៤៩.៤៣៦.២៤៥) | (២២២.៨៤៣.៤៨១) | (៩១២.៣២១.២១១) |
| **ចំណេញដុល** | | **៣០.៤០២.១៦៤** | **១២៣.៨៨៨.៨១៨** | **៤៩.៩២៩.០៣៨** | **២០៤.៤០៩.៤៨២** |
| ចំណូលផ្សេងៗ | | ១.៥១៣.៤២៥ | ៦.១៦៧.២០៧ | ៦៦៤.០០៥ | ២.៧១៨.៤៣៦ |
| ចំណាយប្រតិបត្តិការ | | (៥.៥២៩.៩៧៥) | (២២.៥៣៤.៦៤៨) | (៣.៧២៩.២៣៩) | (១៥.២៦៧.៥០៤) |
| ចំណាយទីផ្សារ | | (២.៩១៩.២៨២) | (១១.៨៩៦.០៧៤) | (៣.៤៥៣.៩៥៨) | (១៤.១៤០.៥០៤) |
| ចំណាយរដ្ឋបាល | | (៧.៣៦២.០២០) | (៣០.០០០.២៣២) | (៦.៧៧៦.៧៧៥) | (២៧.៧៤៤.១១៧) |
| **ចំណេញពីប្រតិបត្តិការ** | | **១៦.១០៤.៣១២** | **៦៥.៦២៥.០៧១** | **៣៦.៦៣៣.០៧១** | **១៤៩.៩៧៥.៧៩៣** |
| ចំណាយហិរញ្ញប្បទាន | | (៣.៣៨៥.៦៦៤) | (១៣.៧៩៦.៥៨១) | (២.៩៤៤.៨៨២) | (១២.០៥៦.៣៤៧) |
| **ចំណេញមុនបង់ពន្ធ** | | **១២.៧១៨.៦៤៨** | **៥១.៨២៨.៤៩០** | **៣៣.៦៨៨.១៨៩** | **១៣៧.៩១៩.៤៤៦** |
| ពន្ធលើប្រាក់ចំណូល | ១២ | (២.៥៨១.៩៥១) | (១០.៥២១.៤៥០) | (៦.០៤៩.០១៥) | (២៤.៧៦៤.៦៦៧) |
| **ចំណេញក្នុងគ្រា** | | **១០.១៣៦.៦៩៧** | **៤១.៣០៧.០៤០** | **២៧.៦៣៩.១៧៤** | **១១៣.១៥៤.៧៧៩** |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| *ធាតុដែលអាចមិនត្រូវបានចាត់ថ្នាក់ ឡើងវិញទៅក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៣.១៤៣.២២៥ | - | ២.២៣២.៨១២ |
| **លទ្ធផលលម្អិតសរុបក្នុងគ្រា** | | **១០.១៣៦.៦៩៧** | **៤៤.៤៥០.២៦៥** | **២៧.៦៣៩.១៧៤** | **១១៥.៣៨៧.៥៩១** |

របាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
# សម្រាប់រយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | លម្អៀងពីការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | មូលធនសរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | | ៤.០០០.០០០ | ១០២.៣៦៤.៥៣៧ | - | ១០៦.៣៦៤.៥៣៧ |
| ចំណេញ និងលទ្ធផលលម្អិតសរុបក្នុងគ្រា | | - | ២៧.៦៣៩.១៧៤ | - | ២៧.៦៣៩.១៧៤ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ភាគលាភ | ១៣ | - | (៣.១៥០.៧៩១) | - | (៣.១៥០.៧៩១) |
| **សមតុល្យនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ (មិនបានធ្វើសវនកម្ម)** | | ៤.០០០.០០០ | ១២៦.៨៥២.៩២០ | - | ១៣០.៨៥២.៩២០ |
| **សមតុល្យនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ (ពាន់រៀល)** | | ១៦.០០០.០០០ | ៥១៧.១៩២.៤២៤ | ៧.២៣០.១៣៦ | ៥៤០.៤២២.៥៦០ |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | | ៤.០០០.០០០ | ១២០.០៨៨.៦០៨ | - | ១២៤.០៨៨.៦០៨ |
| ចំណេញ និងលទ្ធផលលម្អិតសរុបក្នុងគ្រា | | - | ១០.១៣៦.៦៩៧ | - | ១០.១៣៦.៦៩៧ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ភាគលាភ | ១៣ | - | (៨.៩៦៥.០០០) | - | (៨.៩៦៥.០០០) |
| **សមតុល្យនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ (មិនបានធ្វើសវនកម្ម)** | | ៤.០០០.០០០ | ១២១.២៦០.៣០៥ | - | ១២៥.២៦០.៣០៥ |
| **សមតុល្យនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ (ពាន់រៀល)** | | ១៦.០០០.០០០ | ៤៩៤.៥២៦.០៧២ | ៤.២៩៣.៧៨២ | ៥១៤.៨១៩.៨៥៤ |

របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
## សម្រាប់រយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | |
| | កំណត់ | មិនបានធ្វើសវនកម្ម | | មិនបានធ្វើសវនកម្ម | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| **ចំណេញមុនបង់ពន្ធ** | | **១២.៧១៨.៦៤៨** | **៥១.៨២៨.៤៩០** | **៣៣.៦៨៨.១៨៩** | **១៣៧.៩១៩.៤៤៦** |
| **និយ័តកម្មសម្រាប់៖** | | | | | |
| ចំណាយហិរញ្ញប្បទាន | | ៣.៣៨៥.៦៦៤ | ១៣.៧៩៦.៥៨១ | ២.៩៤៤.៨៨២ | ១២.០៥៦.៣៤៧ |
| ចំណូលហិរញ្ញប្បទាន | | (១៩៩.៩១២) | (៨១៤.៦៤១) | (៥១៩.៨២៩) | (២.១២៨.១៨០) |
| ចំណេញពីការប្តូររូបិយប័ណ្ណសុទ្ធ | | (៤.៧២៨) | (១៩.២៦៧) | (៣៥.៩០៥) | (១៤៦.៩៩៥) |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | | | | |
| - រំលស់ | ៥ | ២.០៥០.៦៥០ | ៨.៣៥៦.៣៩៩ | ១.៦៧៣.៦៤១ | ៦.៨៥១.៨៨៦ |
| - ចំណេញពីការលក់ | | (២៥៦.១៥៥) | (១.០៤៣.៨៣២) | (៣៥.៩៦៦) | (១៤៧.២៤៥) |
| ការកត់ត្រាត្រឡប់មកវិញនៃការខាតបង់ ឱនភាពតម្លៃលើគណនីអតិថិជនពាណិជ្ជ | | (១.៦៧៣) | (៦.៨១៧) | (៣.៦៨៦) | (១៥.០៩០) |
| ការកត់ត្រាត្រឡប់មកវិញនៃសំវិធានធន លើការធានា | | - | - | (៩៩៨.០០០) | (៤.០៨៥.៨១២) |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | | | | | |
| - រំលស់ | | ៩៨០.២៣២ | ៣.៩៩៤.៤៤៥ | ៥៨០.៦១៣ | ២.៣៧៧.០៣០ |
| - ការខាតបង់លើការឈប់ទទួលស្គាល់ | | - | - | ១៤.៥៨៨ | ៥៩.៧២៣ |
| សន្និធិដែលមានចលនាយឺតយ៉ាវ | | | | | |
| - សំវិធានធន | ៦ | ៦២៤.៨០៥ | ២.៥៤៦.០៨០ | ៣០០.០០០ | ១.២២៨.២០០ |
| - ការកត់ត្រាត្រឡប់មកវិញនៃសំវិធានធន | ៦ | (២.០០៩.០៨១) | (៨.១៨៧.០០៥) | (១.១៣៦.៨៨៩) | (៤.៦៥៤.៤២៤) |
| - ការលុបចោល | ៦ | (២៤៤.៧៧៧) | (៩៩៧.៤៦៦) | (២០៨.៥០៣) | (៨៥៣.៦១១) |
| **ចំណេញពីប្រតិបត្តិការមុន បម្រែបម្រួលទុនបង្វិល** | | **១៧.០៤៣.៦៧៣** | **៦៩.៤៥២.៩៦៧** | **៣៦.២៦៣.១៣៥** | **១៤៨.៤៦១.២៧៥** |
| **បម្រែបម្រួលទុនបង្វិល៖** | | | | | |
| សន្និធិ | | ៧៤.១៤៤.៧៥៣ | ៣០២.១៣៩.៨៦៨ | (៣៣.២៧៧.១១៧) | (១៣៦.២៣៦.៥១៧) |
| គណនីអតិថិជនពាណិជ្ជ និង គណនីត្រូវទទួលផ្សេងៗ | | ២.០៤៦.៤៥៦ | ៨.៣៣៩.៣០៨ | (១១.៥៤២.៤៨៤) | (៤៧.២៥៤.៩២៩) |
| ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ | | (២.៧៥៥.៨២៤) | (១១.២២៩.៩៨៣) | (៣.៩៧២.១៦៧) | (១៦.២៦២.០៥២) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជ និង គណនីត្រូវទូទាត់ផ្សេងៗ | | ៨.៧១៥.៩៤៦ | ៣៥.៥១៧.៤៨០ | ២.៩១៤.១៣២ | ១១.៩៣០.៤៥៦ |
| ទឹកប្រាក់ជំពាក់ទៅភាគីពាក់ព័ន្ធ | | (២២.១៨១.៩០០) | (៩០.៣៩១.២៤៣) | ១៥.០៦៣.៥៨៩ | ៦១.៦៧០.៣៣៣ |
| បំណុលកិច្ចសន្យា | | ១២៩.៨០៤ | ៥២៨.៩៥១ | (៧.៧៣៣.៦៧០) | (៣១.៦៦១.៦៤៥) |
| **សាច់ប្រាក់សុទ្ធបានពី / (ប្រើប្រាស់ក្នុង) ប្រតិបត្តិការ** | | **៧៧.១៤២.៩០៨** | **៣១៤.៣៥៧.៣៤៨** | **(២.២៨៤.៥៨២)** | **(៩.៣៥៣.០៧៩)** |
| ការប្រាក់បានទទួល | | ១៤៩.៧២៧ | ៦១០.១៣៨ | ១.១១០.៤៤៦ | ៤.៥៤៦.១៦៦ |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២.៧៨៦.៦៣៥) | (១១.៣៥៥.៥៣៨) | (១៣.៧៦៦.៤៨៨) | (៥៦.៣៦០.០០២) |
| **សាច់ប្រាក់សុទ្ធបានពី / (ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | | **៧៤.៥០៦.០០០** | **៣០៣.៦១១.៩៤៨** | **(១៤.៩៤០.៦២៤)** | **(៦១.១៦៦.៩១៥)** |

## អេ អិម អេ (ខេមបូឌា) ម.ក

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល
## សម្រាប់រយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

| | | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | |
| | កំណត់ | មិនបានធ្វើសវនកម្ម | | មិនបានធ្វើសវនកម្ម | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សកម្មភាពវិនិយោគ** | | | | | |
| ការដាក់ប្រាក់បញ្ញើរយៈពេលខ្លី | ៧ | (១០.០០០០.០០០) | (៤០.៧៥០.០០០) | - | - |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (១.៣៨៨.៣៣៣) | (៥.៦៥៧.៤៥៧) | (៤.៥៧៩.២៧៦) | (១៨.៧៤៧.៥៥៦) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ១.០៩៧.៨០៥ | ៤.៤៧៣.៥៥៥ | ៣៧៨.៥៨១ | ១.៥៤៩.៩១១ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | | **(១០.២៩០.៥២៨)** | **(៤១.៩៣៣.៩០២)** | **(៤.២០០.៦៩៥)** | **(១៧.១៩៧.៦៤៥)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ឥណទាន និងប្រាក់កម្ចី | | | | | |
| - ការបោះផ្សាយ | | ២៣.៩៦២.០៣០ | ៩៧.៦៤៥.២៧២ | ៩៦.៧៥២.៦៨៩ | ៣៩៦.១០៥.៥០៩ |
| - ការទូទាត់ប្រាក់ដើម | | (៦៨.១៦០.៦៦៦) | (២៧៧.៧៥៤.៧១៤) | (៩០.៦១៨.៩៧៧) | (៣៧០.៩៩៤.០៩២) |
| - ការប្រាក់បានបង់ | | (៣.០០៧.៧៥១) | (១២.២៥៦.៥៨៥) | (២.១៦៥.២៣៩) | (៨.៨៦៤.៤៨៩) |
| ការទូទាត់នៃបំណុលភតិសន្យា | | | | | |
| - ប្រាក់ដើម | | (៥៨៦.៦១៦) | (២.៣៩០.៤៦០) | (៥៨១.៧៧៥) | (២.៣៨១.៧៨៧) |
| - ការប្រាក់ | | (១.២៣៦.០០០) | (៥.០៣៦.៧០០) | (១៦៣.២០៦) | (៦៦៨.១៦៥) |
| ភាគលាភបានបង់ | ១២ | (៨.៩៦៥.០០០) | (៣៦.៥៣២.៣៧៥) | (៣.១៥០.៧៩១) | (១២.៨៦៧.៨៣០) |
| ការដាក់ប្រាក់ធានាលើសញ្ញាប័ណ្ណ | | (១០.៨៩៥) | (៤៤.៣៩៧) | (៥៨.៧៤៧) | (២៤០.៥១០) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពី សកម្មភាពហិរញ្ញប្បទាន** | | **(៥៨.០០៤.៨៩៨)** | **(២៣៦.៣៦៩.៩៥៩)** | **១៣.៩៥៤** | **៨៨.៦៣៦** |
| **កំណើន/(ថយ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **៦.២១០.៥៧៤** | **២៥.៣០៨.០៨៧** | **(១៩.១២៧.៣៦៥)** | **(៧៨.២៧៥.៩២៤)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី១ ខែមករា** | | **២១.៥៩៨.១៣៥** | **៨៨.២២៨.៣៨១** | **៣៧.៤៩១.៣៦៣** | **១៥៤.៣៥១.៩៤២** |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៧៥៧.៣២៦ | - | (២៣២.៧០៦) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី៣០ ខែមិថុនា** | ៨ | **២៧.៨០៨.៧០៩** | **១១៤.២៩៣.៧៩៤** | **១៨.៣៦៣.៩៩៨** | **៧៥.៨៤៣.៣១២** |

របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល គួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងកំណត់សម្គាល់ពន្យល់ដែលបានភ្ជាប់ក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
# សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

## ១. ព័ត៌មានអំពីក្រុមហ៊ុន

អ អិម អេ (ខេមបូឌា) ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដែលបានចុះបញ្ជីពាណិជ្ជកម្ម និងមានទីស្នាក់ការនៅព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅផ្ទះលេខ២៧E១ ផ្លូវ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការធ្វើទីផ្សារ និងការលក់យានយន្ត គ្រឿងបន្លាស់ គ្រឿងចក្រធុនធ្ងន់ និងការផ្តល់សេវាកម្មជួសជុល និងថែទាំគ្រឿងចក្រធុនធ្ងន់។ ពុំមានការផ្លាស់ប្តូរជាសារវន្តនៃសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងគ្រានេះឡើយ។

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន មិនត្រូវបានធ្វើសវនកម្មទេ ហើយត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនរួមបញ្ចូលគ្រប់កំណត់សម្គាល់ទាំងឡាយណាដែលជាទូទៅត្រូវបានរួមបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ ប៉ុន្តែកំណត់សម្គាល់លម្អិតមួយចំនួនត្រូវបានរួមបញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការ ដែលមានសារៈសំខាន់ដល់ការយល់ដឹងពីបម្រែបម្រួលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុតាំងពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនាការិយបរិច្ឆេទមុន។ អាស្រ័យហេតុនេះ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលគួរតែអានជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសេចក្តីប្រកាសជាសាធារណៈនានា ដែលបានធ្វើឡើងដោយក្រុមហ៊ុនក្នុងអំឡុងគ្រារាយការណ៍ចន្លោះពេល។

គោលការណ៍គណនេយ្យដែលបានអនុវត្ត គឺមានភាពដូចគ្នាទៅនឹងការិយបរិច្ឆេទហិរញ្ញវត្ថុមុន និងគ្រារាយការណ៍ចន្លោះពេលដែលពាក់ព័ន្ធ។

### ការបង្ហាញជាខ្មែររៀល

ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានបង្ហាញជាខ្មែររៀល។ របាយការណ៍លទ្ធផលលម្អិតសង្ខេប និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបត្រូវបានប្តូរជាខ្មែររៀលដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមសម្រាប់រយៈពេល ៣ខែដែលបានបញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ដោយ ១ដុល្លារអាមេរិកស្មើនឹង ៤.០៨០រៀល (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣៖ ៤.១២០រៀល) និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ដោយ ១ដុល្លារអាមេរិកស្មើនឹង ៤.០៧៥រៀល (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣៖ ៤.០៩៤រៀល)។ ទ្រព្យសកម្ម និងបំណុលសម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់ចុងគ្រាគិតត្រឹមកាលការិយបរិច្ឆេទរាយការណ៍ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ដោយ ១ដុល្លារអាមេរិកស្មើនឹង ៤.១១០រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣៖ ៤.០៨៥រៀល)។ ដើមទុនរបស់ភាគទុនិក គឺត្រូវប្តូរនាកាលការិយបរិច្ឆេទប្រតិបត្តិការ។ រាល់ការលម្អៀងពីការប្តូររូបិយប័ណ្ណ ដែលកើតឡើងពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

ការប្តូរប្រាក់ទាំងនេះ មិនគួរត្រូវបានប្រើប្រាស់ជាតំណាងឱ្យចំនួនទឹកប្រាក់ដុល្លារអាមេរិកដែលត្រូវបាន ឬអាចត្រូវបាន ឬនឹងប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ដទៃទៀតឡើយ។

## ៣. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

ក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលទាំងនេះ គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ និងការប៉ាន់ស្មានដែលអាចប៉ះពាល់ដល់ការអនុវត្តគោលការណ៍គណនេយ្យ និងតម្លៃនៃទ្រព្យសកម្ម និងបំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។

ការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក្នុងការអនុវត្តគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុន និងប្រភពគន្លឹះនៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាន គឺដូចគ្នានឹងអ្វីដែលបានពិពណ៌នានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការិយបរិច្ឆេទមុនដែរ។

## ៤. កត្តារដូវកាល ឬវដ្ត

ការប្រតិបត្តិការរបស់ក្រុមហ៊ុនមិនត្រូវបានរងផលប៉ះពាល់ជាសារវន្តដោយកត្តារដូវកាល ឬវដ្តនោះទេ។

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | អាគារ | បរិក្ខារសេវាកម្ម និងបរិក្ខារឃ្លាំង | គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ | ការកែលម្អទ្រព្យជួល | យានយន្ត | បរិក្ខារសម្រាប់ ប្រតិបត្តិការ | ទ្រព្យកំពុងសាងសង់ | សរុប |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | | | |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ៦.៨១០.៦៧១ | ១.៦១០.៣០១ | ១.០៤៣.៣៤៤ | ១.៤២១.០២៦ | ៩.៤៩៨.០៨៤ | ៣.៣៩៩.៣៤១ | ១.៨២៩.៧៥៦ | ២៥.៦១២.៥២៣ |
| ការទិញបន្ថែម | ២.០១១.៥២០ | ៧៦៣.៣៥១ | ១៦៤.៦១៦ | ៤៩៨.៧៧៩ | - | ៩៦១.៥៣៧ | ១.៨៦២.៣៨០ | ៦.២៦២.១៨៣ |
| ការផ្ទេរពីសន្និធិ | - | - | - | - | ៧.៩៦៨.១៧៥ | ៤៣៧.៧១៨ | - | ៨.៤០៥.៨៩៣ |
| ការលក់ | (៣៣៣.៥៦៣) | - | - | - | (២.៧០១.៣០៣) | (២១.៩៤៨) | - | (៣.០៥៦.៨១៤) |
| ការលុបចោល | - | - | - | - | - | (៣.១៧០) | - | (៣.១៧០) |
| ការផ្ទេរទៅសន្និធិ | - | - | - | - | (៤.២៤៤.៦៨២) | (៧១៨.១០៣) | - | (៤.៩៦២.៧៨៥) |
| ការផ្ទេរពីទ្រព្យកំពុងសាងសង់ | ១.៦៥១.៥៣៣ | - | - | ៤៦.៧៤៩ | - | ៤.៦៨០ | (១.៧០២.៩៦២) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | ១០.១៤០.១៦១ | ២.៣៧៣.៦៥២ | ១.២០៧.៩៦០ | ១.៩៦៦.៥៥៤ | ១០.៥២០.២៧៤ | ៤.០៦០.០៥៥ | ១.៩៨៩.១៧៤ | ៣២.២៥៧.៨៣០ |
| ការទិញបន្ថែម | ៥១៨.១៨០ | ១២៥.៥៦៨ | ៣២.៥៧៣ | ២៣១.០៤២ | - | ១២៥.៨៥៣ | ៣៥៥.១១៧ | ១.៣៨៨.៣៣៣ |
| ការផ្ទេរពីសន្និធិ (កំណត់សម្គាល់ ៦) | - | ៨.៨១០ | - | - | ៥.៤៣៦.២០០ | ៣០៤.៨០៦ | - | ៥.៧៤៩.៨១៦ |
| ការលក់ | - | (៣.២៨៨) | - | - | (១.៤៩៨.៧៣១) | (៣.៣៣០) | - | (១.៥០៥.៣៤៩) |
| ការលុបចោល | - | - | - | - | - | (៣.៦១០) | - | (៣.៦១០) |
| ការផ្ទេរទៅសន្និធិ | - | - | - | - | (២.៥៣៤.៨០១) | (៦៩២.៨១៤) | - | (៣.២២៧.៦១៥) |
| ការផ្ទេរពីទ្រព្យកំពុងសាងសង់ | ១.៩៨៩.១៧៤ | - | - | - | - | - | (១.៩៨៩.១៧៤) | - |
| **នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤** | ១២.៦៤៧.៥១៥ | ២.៥០៤.៧៤២ | ១.២៤០.៥៣៣ | ២.១៩៧.៥៩៦ | ១១.៩២២.៩៤២ | ៣.៧៩០.៩៦០ | ៣៥៥.១១៧ | ៣៤.៦៥៩.៤០៥ |

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | អាគារ<br>ដុល្លារអាមេរិក | បរិក្ខារសេវាកម្ម និងបរិក្ខារឃ្លាំង<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់<br>ដុល្លារអាមេរិក | ការកែលម្អទ្រព្យជួល<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារសម្រាប់ប្រតិបត្តិការ<br>ដុល្លារអាមេរិក | ទ្រព្យកំពុងសាងសង់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|
| **រំលស់បង្គរ** | | | | | | | | |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ៣.៩៣៨.៦១៩ | ១.១៧៦.៨៦៧ | ៨៥៨.៦៥៩ | ១.០៨៧.៩៤៤ | ៣.១៩៤.៨១៧ | ២.០៦២.០៩៣ | - | ១២.៣១៨.៩៩៩ |
| រំលស់សម្រាប់ការិយបរិច្ឆេទ | ៦៨៧.០៦៦ | ២១០.២៤២ | ៩៣.៤០១ | ១៤៦.៦៦៣ | ២.០២៦.៥៣៦ | ៥០២.៦៧០ | - | ៣.៦៦៦.៥៧៨ |
| ការលក់ | (២៩៧.០២៩) | - | - | - | (១.៣៤៦.៦០២) | (១៥.៧៧៣) | - | (១.៦៥៩.៤០៤) |
| ការលុបចោល | - | - | - | - | - | (៣.១៧០) | - | (៣.១៧០) |
| ការផ្ទេរទៅសន្និធិ | - | - | - | - | (៧១៥.៩៣១) | (១១៤.៨៧៣) | - | (៨៣០.៨០៤) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | ៤.៣២៨.៦៥៦ | ១.៣៨៧.១០៩ | ៩៥២.០៦០ | ១.២៣៤.៦០៧ | ៣.១៥៨.៨២០ | ២.៤៣០.៩៤៧ | - | ១៣.៤៩២.១៩៩ |
| រំលស់ក្នុងគ្រា | ៥០៣.០៦៧ | ១៥២.៩១៤ | ៥៩.៤៣៨ | ៩៨.៥៩៨ | ៩៩៤.៤៨៤ | ២៤២.១៤៩ | - | ២.០៥០.៦៥០ |
| ការលក់ | - | (៣.២៨៨) | - | - | (៦៥៧.១៣៤) | (៣.២៧៧) | - | (៦៦៣.៦៩៩) |
| ការលុបចោល | - | - | - | - | - | (៣.៦១០) | - | (៣.៦១០) |
| ការផ្ទេរទៅសន្និធិ | - | - | - | - | (៤១៧.៨៧២) | (១០៦.៦៩៩) | - | (៥២៤.៥៧១) |
| **នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤** | ៤.៨៣១.៧២៣ | ១.៥៣៦.៧៣៥ | ១.០១១.៤៩៨ | ១.៣៣៣.២០៥ | ៣.០៧៨.២៩៨ | ២.៥៥៩.៥១០ | - | ១៤.៣៥០.៩៦៩ |
| **តម្លៃយោង** | | | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៥.៨១១.៥០៥ | ៩៨៦.៥៤៣ | ២៥៥.៩០០ | ៧៣១.៩៤៧ | ៧.៣៦១.៤៥៤ | ១.៦២៩.១០៨ | ១.៩៨៩.១៧៤ | ១៨.៧៦៥.៦៣១ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (ពាន់រៀល) | ២៣.៧៣៩.៩៩៨ | ៤.០៣០.០២៨ | ១.០៤៥.៣៥២ | ២.៩៩០.០០៣ | ៣០.០៧១.៥៤០ | ៦.៦៥៤.៩០៦ | ៨.១២៥.៧៧៦ | ៧៦.៦៥៧.៦០៣ |
| នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ | ៧.៨១៥.៧៩២ | ៩៦៨.០០៧ | ២២៩.០៣៥ | ៨៦៤.៣៩១ | ៨.៨៤៤.៦៤៤ | ១.២៣១.៤៥០ | ៣៥៥.១១៧ | ២០.៣០៨.៤៣៦ |
| នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ (ពាន់រៀល) | ៣២.១២២.៩០៥ | ៣.៩៧៨.៥០៩ | ៩៤១.៣៣៤ | ៣.៥៥២.៦៤៧ | ៣៦.៣៥១.៤៨៧ | ៥.០៦១.២៦០ | ១.៤៥៩.៥៣០ | ៨៣.៤៦៧.៦៧២ |

## ៦. សន្និធិ

ថ្លៃដើមនៃសន្និធិរបស់ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថា ជាការចំណាយលើថ្លៃដើមនៃការលក់ក្នុងសម្រាប់រយៈពេល ៦ខែបញ្ចប់ មានចំនួន ១៧៩.៤៩៣.៥៩១ដុល្លារអាមេរិក (២០២៣៖ ២១៨.៧១៥.១៥៦ដុល្លារអាមេរិក)។

### សន្និធិដែលមានចលនាយឺតយ៉ាវ

ក្នុងអំឡុងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ក្រុមហ៊ុនបានទទួលស្គាល់សំវិធានធនលើសន្និធិដែលមានចលនាយឺតយ៉ាវចំនួន ៦២៤.៨០៥ដុល្លារអាមេរិក (ស្មើនឹង ២.៥៤៦.០៨០.០០០រៀល) (២០២៣៖ ៣០០.០០០ដុល្លារអាមេរិក (ស្មើនឹង ១.២២៨.២០០.០០០រៀល)) ប៉ុន្តែក្រុមហ៊ុនបានធ្វើការកត់ត្រាត្រឡប់មកវិញនូវសន្និធិពីមុនរបស់ខ្លួនមានចំនួន ២.០០៩.០៨១ដុល្លារអាមេរិក (ស្មើនឹង ៨.១៨៧.០០៥.០០០រៀល) (២០២៣៖ ១.១៣៦.៨៨៩ដុល្លារអាមេរិក (ស្មើនឹង ៤.៦៥៤.៤២៤.០០០រៀល)) ដោយសារតែការលក់ចេញនូវសន្និធិដែលបានលុបចោលពីមុនៗ។ ការកត់ត្រាត្រឡប់មកវិញត្រូវបានបញ្ចូលក្នុងចំណាយប្រតិបត្តិការនៅក្នុងរបាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេល។

សន្និធិត្រូវបានកំណត់តាមតម្លៃពិតជាក់ស្តែងសុទ្ធ។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ក្រុមហ៊ុនបានធ្វើសំវិធានធនលើសន្និធិដែលមានចលនាយឺតយ៉ាវចំនួន ២.៦១៨.៧៩០ដុល្លារអាមេរិក (ស្មើនឹង ១០.៧៦៣.២២៧.០០០រៀល)។ ការលុបចោលនៃសន្និធិចំនួន ២៤៤.៧៧៧ដុល្លារអាមេរិក (ស្មើនឹង ៩៩៧.៤៦៦.០០០រៀល) (២០២៣៖ ២០៨.៥០៣ដុល្លារអាមេរិក (ស្មើនឹង ៨៥៣.៦១១.០០០រៀល)) គឺត្រូវបានបញ្ចូលក្នុងចំណាយប្រតិបត្តិការនៅក្នុងរបាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេលផងដែរ។

### ការផ្ទេរទៅ / ពីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ក្នុងអំឡុងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ក្រុមហ៊ុនបានធ្វើការផ្ទេរសន្និធិរបស់ខ្លួនទៅទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារចំនួន ៥.៧៤៩.៨១៦ដុល្លារអាមេរិក (ស្មើនឹង ២៣.៦៣១.៧៤៤.០០០រៀល) (២០២៣៖ ៣.៥៦៥.៤៧៤ដុល្លារអាមេរិក (ស្មើនឹង ១៤.៧២៥.៤០៨.០០០រៀល)) ដោយសារសន្និធិទាំងនេះ ពុំមានការលក់ក្នុងប្រតិបត្តិការអាជីវកម្មទៀតនោះទេ ដោយជាចេតនាទុកសម្រាប់តាំងបង្ហាញវិញ។

ក្នុងអំឡុងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ក្រុមហ៊ុនបានធ្វើការផ្ទេរទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ខ្លួនមួយចំនួន ទៅសន្និធិដែលមានចំនួនសុទ្ធ ២.៧០៣.០៤៤ដុល្លារអាមេរិក (ស្មើនឹង ១១.១០៩.៥១១.០០០រៀល) (២០២៣៖ ១.៣៤៤.៨២៨ដុល្លារអាមេរិក (ស្មើនឹង ៥.៥៥៤.១៤០.០០០រៀល)) ដោយចេតនាប្រើប្រាស់ពីដំបូងទុកសម្រាប់ការតាំងបង្ហាញ បន្ទាប់មកគឺត្រូវបានលក់ទៅឱ្យអតិថិជនវិញ។

## ៧. ប្រាក់បញ្ញើរយៈពេលខ្លី

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ច្រើនជាង ៣ខែ តែតិចជាង ១២ខែ | ៥.០០០.០០០ | ២០.៥៥០.០០០ | - | - |
| ក្នុងរយៈពេល ១២ខែ | ៥.០០០.០០០ | ២០.៥៥០.០០០ | - | - |
| | ១០.០០០.០០០ | ៤១.១០០.០០០ | - | - |

ទាំងនេះតំណាងឱ្យប្រាក់បញ្ញើរយៈពេលខ្លីដែលបានតម្កល់ទុកជាមួយធនាគារដែលមានកិត្យានុភាព និងមានលក្ខខណ្ឌកាលកំណត់ចាប់ពី ៦ ដល់ ១២ខែជាមួយនឹងអត្រាការប្រាក់ចាប់ពី ៣,២៥% ទៅ ៥,៥០% ក្នុងមួយឆ្នាំ។

## ៨. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ២៨.៣៧៩.០៧៤ | ១១៦.៦៣៧.៩៩៤ | ២២.១៥៧.៦០៥ | ៩០.៥១៣.៨១៦ |
| ប្រាក់បញ្ញើមានកាលកំណត់ ជាមួយធនាគារ | ៥.០០០ | ២០.៥៥០ | ៥.០០០ | ២០.៤២៥ |
| សមតុល្យក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣០ ខែមិថុនា / ថ្ងៃទី៣១ ខែធ្នូ | ២៨.៣៨៤.០៧៤ | ១១៦.៦៥៨.៥៤៤ | ២២.១៦២.៦០៥ | ៩០.៥៣៤.២៤១ |
| ការធានាលើសញ្ញាប័ណ្ណ CGIF | (៥៧៥.៣៦៥) | (២.៣៦៤.៧៥០) | (៥៦៤.៤៧០) | (២.៣០៥.៨៦០) |
| សមតុល្យក្នុងរបាយការណ៍ លំហូរសាច់ប្រាក់ នាថ្ងៃទី៣០ ខែមិថុនា / ថ្ងៃទី៣១ ខែធ្នូ | ២៧.៨០៨.៧០៩ | ១១៤.២៩៣.៧៩៤ | ២១.៥៩៨.១៣៥ | ៨៨.២២៨.៣៨១ |

សាច់ប្រាក់ និងសមតុល្យធនាគាររបស់ក្រុមហ៊ុនរួមមានទឹកប្រាក់ការធានាលើសញ្ញាប័ណ្ណចំនួន ៥៧៥.៣៦៥ដុល្លារអាមេរិក (ស្មើនឹង ២.៣៦៤.៧៥០.០០០រៀល) (២០២៣៖ ៥៦៤.៤៧០ដុល្លារអាមេរិក (ស្មើនឹង ២.៣០៥.៨៦០.០០០រៀល)) ដែលកាន់កាប់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ទាក់ទងនឹងកម្មវិធីវិនិយោគ និងធានាឥណទាន (ដែលហៅកាត់ថា "CGIF") ដូច្នោះហើយទើបទឹកប្រាក់នេះមិនអាចប្រើប្រាស់ជាទូទៅដោយក្រុមហ៊ុនបានទេ។

## ៩. បំណុលកិច្ចសន្យា

បំណុលកិច្ចសន្យាជាចម្បងទាក់ទងនឹងសាច់ប្រាក់បុរេប្រទាន ដែលទទួលបានពីអតិថិជនសម្រាប់ជាប្រាក់កក់លើយានយន្ត និងគ្រឿងចក្រធុនធ្ងន់ និងសេវាដែលមិនទាន់ផ្តល់លើយានយន្ត និងគ្រឿងចក្រធុនធ្ងន់ ដែលចំណូលត្រូវបានទទួលស្គាល់ ហើយនឹងការចេញវិក្កយបត្រលើសពីចំណូលដែលបានទទួលស្គាល់មកដល់បច្ចុប្បន្ន។ បំណុលកិច្ចសន្យាត្រូវបានទទួលស្គាល់ជាប្រាក់ចំណូលនៅពេលដែលក្រុមហ៊ុនបានបំពេញកាតព្វកិច្ចអនុវត្តក្រោមកិច្ចសន្យា។

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា | ៤.៧០៣.៦៩២ | ១៩.២១៤.៥៨២ | ១៣.៥១៨.៤៤៩ | ៥៥.៦៥៥.៤៥៥ |
| ដក៖ ចំណូលទទួលស្គាល់ក្នុងគ្រា / ការិយបរិច្ឆេទដែលរួមបញ្ចូល បំណុលកិច្ចសន្យាដើមគ្រា | | | | |
| - ប្រាក់កក់ពីអតិថិជន | (១.៥៦១.៥៣៧) | (៦.៣៦៣.២៦៣) | (៩.៣៤២.០៦២) | (៣៨.៣៩៥.៨៧៥) |
| - សេវាដែលមិនទាន់ផ្តល់ | (២.៦២៥.២៥៥) | (១០.៦៩៧.៩១៤) | (៤.៤២៨.៩៥២) | (១៨.២០២.៩៩៣) |
| បូក៖ សាច់ប្រាក់បុរេប្រទាន ដែលបានទទួល | | | | |
| - ប្រាក់កក់ពីអតិថិជន | ២.១៤៨.៤៤៣ | ៨.៧៥៤.៩០៥ | ១.៦១៦.៦៤៨ | ៦.៦៤៤.៤២៣ |
| - សេវាដែលមិនទាន់ផ្តល់ | ២.១៦៨.១៥៣ | ៨.៨៣៥.២២៣ | ៣.៣៣៩.៦០៩ | ១៣.៧២៥.៧៩៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១២២.១៣៦ | - | (២១២.២២១) |
| នាថ្ងៃទី៣០ ខែមិថុនា / ថ្ងៃទី៣១ ខែធ្នូ | ៤.៨៣៣.៤៩៦ | ១៩.៨៦៥.៦៦៩ | ៤.៧០៣.៦៩២ | ១៩.២១៤.៥៨២ |
| | | | | |
| សាច់ប្រាក់បុរេប្រទានដែលបានទទួល | ៣.០៣៣.១៤៤ | ១២.៤៦៦.២២២ | ២.៤៤៦.២៣៨ | ៩.៩៩២.៨៨១ |
| សេវាដែលមិនទាន់ផ្តល់ | ១.៨០០.៣៥២ | ៧.៣៩៩.៤៤៧ | ២.២៥៧.៤៥៤ | ៩.២២១.៧០១ |
| | ៤.៨៣៣.៤៩៦ | ១៩.៨៦៥.៦៦៩ | ៤.៧០៣.៦៩២ | ១៩.២១៤.៥៨២ |

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

### ១០. ឥណទាន និងប្រាក់កម្ចី

| | | | | តម្លៃយោង | |
|---|---|---|---|---|---|
| | រូបិយប័ណ្ណ | អត្រាការប្រាក់ធម្មតា | កាលកំណត់ | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ | | | | ៧៧.៣៣៣.៤០៧ | ៣១៥.៩០៦.៩៦៨ |
| **ការបោះផ្សាយ** | | | | | |
| ហិរញ្ញប្បទានពាណិជ្ជកម្ម I | ដុល្លារអាមេរិក | EURIBOR / SOFR + ៦,៧៩% ដល់ ៦,៨៤%ក្នុងមួយឆ្នាំ | ៩០ - ១៨០ថ្ងៃរាល់ពេលបោះផ្សាយ | ១៥.១៥៧.៣០៩ | ៦១.៧៦៦.០៣៣ |
| ហិរញ្ញប្បទានពាណិជ្ជកម្ម II | ដុល្លារអាមេរិក | ៨,៥% ក្នុងមួយឆ្នាំ | ៩០ថ្ងៃរាល់ពេលបោះផ្សាយ | ១.០២៥.៧០០ | ៤.១៧៩.៧២៨ |
| ហិរញ្ញប្បទានពាណិជ្ជកម្ម III | ដុល្លារអាមេរិក | ៧,៥% ក្នុងមួយឆ្នាំ | ៩០ថ្ងៃរាល់ពេលបោះផ្សាយ | ១.៦៣០.៥១៩ | ៦.៦៤៤.៣៦៥ |
| ហិរញ្ញប្បទានពាណិជ្ជកម្ម IV | ដុល្លារអាមេរិក | ៨% ក្នុងមួយឆ្នាំ | ១៨០ថ្ងៃរាល់ពេលបោះផ្សាយ | ៦.១៤៨.៥០២ | ២៥.០៥៥.១៤៦ |
| **ការទូទាត់សង** | | | | | |
| មូលបត្របំណុលសាជីវកម្ម | រៀល | ៥,៥% ក្នុងមួយឆ្នាំ | ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥ | (៤.៩៣៥.៧២៦) | (២០.១១៣.០៨៣) |
| ហិរញ្ញប្បទានពាណិជ្ជកម្ម I | ដុល្លារអាមេរិក | EURIBOR / SOFR + ៦,៧៩% ដល់ ៦,៨៤% ក្នុងមួយឆ្នាំ | ៩០ - ១៨០ថ្ងៃរាល់ពេលបោះផ្សាយ | (៣៧.០៤៤.៩៤៧) | (១៥០.៩៥៨.១៥៩) |
| ហិរញ្ញប្បទានពាណិជ្ជកម្ម II | ដុល្លារអាមេរិក | ៨,៥% ក្នុងមួយឆ្នាំ | ៩០ថ្ងៃរាល់ពេលបោះផ្សាយ | (៥.៩៧៤.០១០) | (២៤.៣៤៤.០៩១) |
| ហិរញ្ញប្បទានពាណិជ្ជកម្ម III | ដុល្លារអាមេរិក | ៧,៥% ក្នុងមួយឆ្នាំ | ៩០ថ្ងៃរាល់ពេលបោះផ្សាយ | (២.៦២៣.២៨៣) | (១០.៦៨៩.៨៧៨) |
| ហិរញ្ញប្បទានពាណិជ្ជកម្ម IV | ដុល្លារអាមេរិក | ៨% ក្នុងមួយឆ្នាំ | ១៨០ថ្ងៃរាល់ពេលបោះផ្សាយ | (១៦.០៨២.៧០០) | (៦៥.៥៣៧.០០៣) |
| ឥណទានមានកាលកំណត់ | ដុល្លារអាមេរិក | SOFR + ២,៥% ដល់ ២,៨៥% ក្នុងមួយឆ្នាំ | ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៨ | (១.៥០០.០០០) | (៦.១១២.៥០០) |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | រៀល | | | - | ៣៨៦.៣៨៣ |
| **សមតុល្យនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤** | | | | ៣៣.១៣៤.៧៧១ | ១៣៦.១៨៣.៩០៩ |
| **ដកៈ ចំណែករយៈពេលខ្លី** | | | | (៧.៦៣៤.៧៧១) | (៣១.៣៧៨.៩០៩) |
| **ចំណែករយៈពេលវែង** | | | | ២៥.៥០០.០០០ | ១០៤.៨០៥.០០០ |

## ១១. ចំណូល

| | រយៈពេល ៣ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤<br>មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣<br>មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ការបែងចែកចំណូលបានមកពីកិច្ចសន្យាជាមួយអតិថិជន៖** | | | | |
| ការលក់ទំនិញ | ១០២.៣៣៦.៤៩០ | ៤១៧.៥៣២.៨៧៩ | ១១៤.៣៥១.១១៦ | ៤៧១.១២៦.៥៩៨ |
| ចំណូលពីសេវាកម្ម | ៥.៨៣១.៦២៨ | ២៣.៧៩៣.០៤២ | ៣.៨៦៩.៩០៧ | ១៥.៩៤៤.០១៧ |
| | ១០៨.១៦៨.១១៨ | ៤៤១.៣២៥.៩២១ | ១១៨.២២១.០២៣ | ៤៨៧.០៧០.៦១៥ |

| | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤<br>មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣<br>មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ការបែងចែកចំណូលបានមកពីកិច្ចសន្យាជាមួយអតិថិជន៖** | | | | |
| ការលក់ទំនិញ | ២០៣.៥០៥.៣១៣ | ៨២៩.២៨៤.១៥០ | ២៦៤.៩៤៨.៤០៦ | ១.០៨៤.៦៩៨.៧៧៤ |
| ចំណូលពីសេវាកម្ម | ១០.៨០៧.៥៨៦ | ៤៤.០៤០.៩១៣ | ៧.៨២៤.១១៣ | ៣២.០៣១.៩១៩ |
| | ២១៤.៣១២.៨៩៩ | ៨៧៣.៣២៥.០៦៣ | ២៧២.៧៧២.៥១៩ | ១.១១៦.៧៣០.៦៩៣ |

## ១២. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងទឹកប្រាក់ ដែលបានគណនាដោយយកប្រាក់ចំណេញមុនបង់ពន្ធសម្រាប់រយៈពេលរាយការណ៍ចន្លោះពេល គុណនឹងអត្រាពន្ធលើប្រាក់ចំណូលមធ្យមប្រចាំឆ្នាំដែលបានរំពឹងទុកសម្រាប់ពេញមួយឆ្នាំសារពើពន្ធ ដែលបានប៉ាន់ស្មានដ៏សមស្របបំផុតរបស់គណៈគ្រប់គ្រង ហើយធ្វើនិយ័តកម្មលើផលប៉ះពាល់ពន្ធលើកត្តាមួយចំនួនដែលបានទទួលស្គាល់ទាំងស្រុងក្នុងគ្រា។ ដូច្នេះអត្រាពន្ធប្រសិទ្ធិភាពនៅក្នុងព័ត៌មានហិរញ្ញវត្ថុចន្លោះពេល អាចខុសគ្នាពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រងលើអត្រាពន្ធប្រសិទ្ធិភាព សម្រាប់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

អត្រាពន្ធប្រសិទ្ធិភាពរបស់ក្រុមហ៊ុនសម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ គឺ២០% (សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ១៨%)។

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

## ១៣. ភាគលាភ

| | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទទួលស្គាល់ក្នុងអំឡុងគ្រាហិរញ្ញវត្ថុ៖** | | | | |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣១ ខែមីនា តម្លៃ ៥.០០០ដុល្លារអាមេរិក (២០.៣៧៥.០០០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ ខ) | ៥.០០០.០០០ | ២០.៣៧៥.០០០ | - | - |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣០ ខែមិថុនា តម្លៃ ១.៨៨០ដុល្លារអាមេរិក (៧.៦៦១.០០០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ គ) | ១.៨៨០.០០០ | ៧.៦៦១.០០០ | - | - |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣០ ខែមិថុនា តម្លៃ ៥៤០ដុល្លារអាមេរិក (២.២០០.៥០០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ (ក)(i)) | ៥៤០.០០០ | ២.២០០.៥០០ | - | - |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣០ ខែមិថុនា តម្លៃ ៤៨០ដុល្លារអាមេរិក (១.៩៥៦.០០០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ (ក)(ii)) | ៤៨០.០០០ | ១.៩៥៦.០០០ | - | - |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣០ ខែមិថុនា តម្លៃ ៣៦០ដុល្លារអាមេរិក (១.៤៦៧.០០០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ (ក)(iii)) | ៣៦០.០០០ | ១.៤៦៧.០០០ | - | - |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣០ ខែមិថុនា តម្លៃ ៥១៨ដុល្លារអាមេរិក (២.១១០.៨៥០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ ឃ) | ៥១៨.០០០ | ២.១១០.៨៥០ | - | - |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣០ ខែមិថុនា តម្លៃ ១៨៧ដុល្លារអាមេរិក (៧៦២.០២៥រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ ង) | ១៨៧.០០០ | ៧៦២.០២៥ | - | - |

## ១៣. ភាគលាភ (ត)

| | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទទួលស្គាល់ក្នុងអំឡុងគ្រាហិរញ្ញវត្ថុ៖** | | | | |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣១ ខែមីនា តម្លៃ ២.៥០០ ដុល្លាអាមេរិក (១០.២១០.០០០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ (ច)(i)) | - | - | ២.៥០០.០០០ | ១០.២១០.០០០ |
| ភាគលាភដែលបានប្រកាស និងទូទាត់ ក្នុងអំឡុងគ្រាបញ្ចប់ថ្ងៃទី៣១ ខែមីនា តម្លៃ ៦៥១ដុល្លាអាមេរិក (២.៦៥៧.៨៣០រៀល) ក្នុងភាគហ៊ុនធម្មតា (កំណត់សម្គាល់ (ច)(ii)) | - | - | ៦៥០.៧៩១ | ២.៦៥៧.៨៣០ |
| | ៨.៩៦៥.០០០ | ៣៦.៥៣២.៣៧៥ | ៣.១៥០.៧៩១ | ១២.៨៦៧.៨៣០ |

(ក) នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរថាភាគលាភចន្លោះពេលប្រចាំខែសម្រាប់ការិយបរិច្ឆេទ២០២៤ សមមូលនឹង ឬតិចជាង ២០% នៃចំណូលសុទ្ធដែលទទួលបានក្នុងខែជាក់លាក់មួយនឹងត្រូវទូទាត់ឱ្យភាគទុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះនៃសមាជិករបស់ក្រុមហ៊ុននាដំណាច់ខែដដែលនេះស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

(i) ភាគលាភចន្លោះពេលប្រចាំខែចំនួន ៥៤០.០០០ដុល្លារអាមេរិក (ស្មើនឹង ២.២០០.៥០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២៤។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤។

(ii) ភាគលាភចន្លោះពេលប្រចាំខែចំនួន ៤៨០.០០០ដុល្លារអាមេរិក (ស្មើនឹង ១.៩៥៦.០០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃខែមីនា ឆ្នាំ២០២៤។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤។

(iii) ភាគលាភចន្លោះពេលប្រចាំខែចំនួន ៣៦០.០០០ដុល្លារអាមេរិក (ស្មើនឹង ១.៤៦៧.០០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃខែមេសា ឆ្នាំ២០២៤។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤។

(ខ) នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ភាគលាភចន្លោះពេលបន្ថែមប្រចាំខែចំនួន ៥.០០០.០០០ដុល្លារអាមេរិក (ស្មើនឹង ២០.៣៧៥.០០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃការិយបរិច្ឆេទបញ្ចប់ឆ្នាំ២០២៣។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤។

## ១៣. ភាគលាភ (ត)

(គ) នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ភាគលាភចន្លោះពេលបន្ថែមប្រចាំខែចំនួន ១.៨៨០.០០០ដុល្លារអាមេរិក (ស្មើនឹង ៧.៦៦១.០០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលសម្រាប់ការិយបរិច្ឆេទបញ្ចប់ឆ្នាំ២០២៣។ ភាគលាភនេះត្រូវបានទូទាត់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤។

(ឃ) នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ ភាគលាភចន្លោះពេលបន្ថែមប្រចាំខែចំនួន ៥១៨.០០០ដុល្លារអាមេរិក (ស្មើនឹង ២.១១០.៨៥០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃខែមីនា ឆ្នាំ២០២៤។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤។

(ង) នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ ភាគលាភចន្លោះពេលបន្ថែមប្រចាំខែចំនួន ១៨៧.០០០ដុល្លារអាមេរិក (ស្មើនឹង ៧៦២.០២៥.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃខែមេសា ឆ្នាំ២០២៤។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤។

(ច) នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាលបានចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរថាភាគលាភចន្លោះពេលប្រចាំខែសម្រាប់ការិយបរិច្ឆេទ២០២២ សមមូលនឹង ឬតិចជាង ២០% នៃចំណូលសុទ្ធដែលទទួលបានក្នុងខែជាក់លាក់មួយនឹងត្រូវទូទាត់ឱ្យភាគទុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះនៃសមាជិករបស់ក្រុមហ៊ុននាដំណាច់ខែដដែលនេះ ស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

- (i) នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ ភាគលាភចន្លោះពេលបន្ថែមប្រចាំខែចំនួន ២.៥០០.០០០ដុល្លារអាមេរិក (ស្មើនឹង ១០.២១០.០០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលនៃរយៈពេល ៩ខែ បញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

- (ii) នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ភាគលាភចន្លោះពេលប្រចាំខែចំនួន ៦៥០.៧៩១ដុល្លារអាមេរិក (ស្មើនឹង ២.៦៥៧.៨៣០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលសម្រាប់ខែធ្នូ ឆ្នាំ២០២២។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣។

## ១៤. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

ក្រុមហ៊ុនមានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖

(ក) ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ៖

| | រយៈពេល ៣ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ជាមួយក្រុមហ៊ុនមេកាន់កាប់ផ្ទាល់** | | | | |
| ភាគលាភ | ៣.៩៦១.០៣៥ | ១៦.១៦១.០២៣ | - | - |
| **ជាមួយភាគទុនិក** | | | | |
| ភាគលាភ | ៣.៩៦៥ | ១៦.១៧៧ | - | - |
| **ជាមួយញាតិសម្ព័ន្ធ** | | | | |
| ចំណាយថ្លៃជួលពី | ៦២.១២៥ | ២៥៣.៤៧០ | - | - |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាទៅ | (៧៦.៣៤៤) | (៣១១.៤៨៤) | (១០១.៧៩២) | (៤១៩.៣៨៣) |
| ការទិញទំនិញ និងសេវាកម្ម | ៩.៦៣០.១០៥ | ៣៩.២៤២.៦៧៨ | ៣៦.៤៦០.២៧២ | ១៥០.២១៦.៣២១ |
| ការទិញទ្រព្យសកម្ម | ២៥៤.៣៦៥ | ១.០៣៧.៨០៩ | - | - |
| ការលក់ទំនិញ និងសេវាកម្ម | (៩៦៥) | (៣.៩៣៧) | (២៧.១៤៦) | (១១១.៨៤២) |
| **ជាមួយបុត្រសម្ព័ន្ធក្រោមក្រុមហ៊ុនមេរួម និងភាគីពាក់ព័ន្ធផ្សេងៗ** | | | | |
| ចំណាយថ្លៃជួលពី | ៤២០.០០០ | ១.៧១៣.៦០០ | ២.២៥០ | ៩.២៧០ |
| ចំណាយថ្លៃជួលទៅ | (៤.៩៥០) | (២០.១៩៦) | (៤.៩៥០) | (២០.៣៩៤) |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាពី | ៨៧៥.៤៤៣ | ៣.៥៧១.៨០៧ | ៦០៨.៩០៩ | ២.៥០៨.៧០៥ |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាទៅ | (១១៩.៨១៣) | (៤៨៨.៨៣៧) | (១០៤.៤៣២) | (៤៣០.២៦០) |
| ការទិញទ្រព្យសកម្ម | ១៣៦.៩៧៤ | ៥៥៨.៨៥៤ | ៥៥២.៦៤៦ | ២.២៧៦.៩០២ |
| ការទិញទំនិញ និងសេវាកម្ម | ១.២៨៤.៧២៥ | ៥.២៤១.៦៧៨ | ២.១០៩.១០៣ | ៨.៦៨៩.៥០៤ |
| ការលក់ទំនិញ និងសេវាកម្ម | (១២.៣១៨.៤៦៩) | (៥០.២៥៩.៣៥៤) | (៩.៧៨៥.៨៣៧) | (៤០.៣១៧.៦៤៨) |
| ការប្រាក់បានបង់ | ២៨៧.៩៩៤ | ១.១៧៥.០១៦ | - | - |
| កម្រៃជើងសារ | (៩.៤៧៩) | (៣៨.៦៧៤) | - | - |

## ១៤. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

ក្រុមហ៊ុនមានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖ (ត)

| | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ជាមួយក្រុមហ៊ុនមេកាន់កាប់ផ្ទាល់** | | | | |
| ភាគលាភ | ៨.៩៥៦.០៣៥ | ៣៦.៤៩៥.៨៤៣ | ៣.១៤៧.៦៤០ | ១២.៨៥៤.៩៦២ |
| **ជាមួយភាគទុនិក** | | | | |
| ភាគលាភ | ៨.៩៦៥ | ៣៦.៥៣២ | ៣.១៥១ | ១២.៨៦៨ |
| **ជាមួយញាតិសម្ព័ន្ធ** | | | | |
| ចំណាយថ្លៃជួលពី | ៧៤.៥៥០ | ៣០៤.១៦៤ | - | - |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាទៅ | (១៥២.៦៨៨) | (៦២២.២០៤) | (១៥៣.០៩១) | (៦២៦.៧៥៥) |
| ការទិញទំនិញ និងសេវាកម្ម | ២២.៨៦១.៨៤៧ | ៩៣.១៦២.០២៧ | ៦៩.៦៦៤.២១០ | ២៨៥.២០៥.២៧៦ |
| ការប្រាក់បានបង់ | ៨៤.៤៧០ | ៣៤៤.២១៥ | - | - |
| ការលក់ទំនិញ និងសេវាកម្ម | (២.៨៤៥) | (១១.៥៩៣) | (២២១.៩៩២) | (៩០៦.៧៨៨) |
| **ជាមួយបុត្រសម្ព័ន្ធក្រោមក្រុមហ៊ុនមេរួម និងភាគីពាក់ព័ន្ធផ្សេងៗ** | | | | |
| ចំណាយថ្លៃជួលពី | ៨៤០.០០០ | ៣.៤២៣.០០០ | ៤.៥០០ | ១៨.៤២៣ |
| ចំណាយថ្លៃជួលទៅ | (៩.៩០០) | (៤០.៣៤៣) | (១០.៦៥០) | (៤៣.៦០១) |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាពី | ១.៩៤៤.៨១៨ | ៧.៩២៥.១៣៣ | ១.៤២៥.៨៧៤ | ៥.៨៣៧.៥២៨ |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាទៅ | (២១៤.៤៩៨) | (៨៧៤.០៧៩) | (២០៩.៤៨៩) | (៨៥៧.៦៤៨) |
| ការទិញទ្រព្យសកម្ម | ២៥៤.៣៦៥ | ១.០៣៦.៥៣៧ | ៧៩០.២៨៨ | ៣.២៣៥.៤៣៩ |
| ការទិញទំនិញ និងសេវាកម្ម | ២.៧៩២.៨៤៤ | ១១.៣៨០.៨៣៩ | ៣.៧១១.៦៤១ | ១៥.១៩៥.៤៥៨ |
| ការលក់ទ្រព្យសកម្ម | (៧០.៩០៩) | (២៨៨.៩៥៤) | (២១.៨១៨) | (៨៩.៣២៣) |
| ការលក់ទំនិញ និងសេវាកម្ម | (២៦.៤៥៧.៩០៦) | (១០៧.៨១៥.៩៦៧) | (២០.៩៣១.៤៥៦) | (៨៥.៦៩៣.៣៨១) |
| ការប្រាក់បានបង់ | ៣០៤.៣១០ | ១.២៤០.០៦៣ | - | - |
| កម្រៃជើងសារ | (១៧.៤៤១) | (៧១.០៧២) | - | - |

## ១៤. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

ក្រុមហ៊ុនមានប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖ (ត)

(ខ) លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗ

| | រយៈពេល ៣ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ឈ្នួល និងប្រាក់បៀវត្ស | ៤៧៧.២៩៨ | ១.៩៤៧.៣៧៦ | ៤៦៨.៦៣៨ | ១.៩៣០.៧៨៩ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ៣៨.០៨៨ | ១៥៥.៣៩៩ | ៣៥.៥៨៨ | ១៤៦.៦២៣ |
| អត្ថប្រយោជន៍ផ្សេងៗ | ២៥.១២៥ | ១០២.៥១០ | ៣៣.៦៨២ | ១៣៨.៧៧០ |
| | ៥៤០.៥១១ | ២.២០៥.២៨៥ | ៥៣៧.៩០៨ | ២.២១៦.១៨២ |

| | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ឈ្នួល និងប្រាក់បៀវត្ស | ៨៧៥.០១២ | ៣.៥៦៥.៦៧៤ | ៨៣៨.០៥៤ | ៣.៤៣០.៩៩៣ |
| លាភការរបស់ក្រុមប្រឹក្សាភិបាល | ៧៣.៦៧៦ | ៣០០.២៣០ | ៧៣.៦៧៦ | ៣០១.៦៣០ |
| អត្ថប្រយោជន៍ផ្សេងៗ | ៥៤.២១៧ | ២២០.៩៣៤ | ៦៤.៨៩៤ | ២៦៥.៦៧៦ |
| | ១.០០២.៩០៥ | ៤.០៨៦.៨៣៨ | ៩៧៦.៦២៤ | ៣.៩៩៨.២៩៩ |

## ១៥. ឧបករណ៍ហិរញ្ញវត្ថុ – តម្លៃសមស្រប និងការគ្រប់គ្រងហានិភ័យ

តម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ មិនមានភាពខុសគ្នាជាសារវន្តពីតម្លៃយោង ដោយសារវាមានរយៈពេលខ្លី ឬក៏អត្រាការប្រាក់មានភាពប្រហាក់ប្រហែលនឹងអត្រាទីផ្សារបច្ចុប្បន្ន។

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

## ១៦. ព័ត៌មានតាមផ្នែក

តារាងខាងក្រោមបង្ហាញពីព័ត៌មានតាមផ្នែក សម្រាប់ផ្នែកដែលអាចរាយការណ៍បានសម្រាប់រយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ និងឆ្នាំ២០២៣៖

| | ក្រុមហ៊ុន ហ្វង | | ប្រតិបត្តិការផ្សេងៗ | | ការលុបបំបាត់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **មិនបានធ្វើសវនកម្ម** | | | | | | | | |
| **រយៈពេល ៦ខែ បញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤** | | | | | | | | |
| ចំណូលតាមផ្នែកសរុប | ១៨៤.៤៦៩.៤០៣ | ៧៥១.៧១២.៨១៧ | ៣៤.៣៧៩.៩៨៧ | ១៤០.០៩៨.៤៤៧ | - | - | ២១៨.៨៤៩.៣៩០ | ៨៩១.៨១១.២៦៤ |
| ចំណូលតាមផ្នែកអន្តរ | - | - | - | - | (៤.៥៣៦.៤៩១) | (១៨.៤៨៦.២០១) | (៤.៥៣៦.៤៩១) | (១៨.៤៨៦.២០១) |
| | ១៨៤.៤៦៩.៤០៣ | ៧៥១.៧១២.៨១៧ | ៣៤.៣៧៩.៩៨៧ | ១៤០.០៩៨.៤៤៧ | (៤.៥៣៦.៤៩១) | (១៨.៤៨៦.២០១) | ២១៤.៣១២.៨៩៩ | ៨៧៣.៣២៥.០៦៣ |
| ចំណូលពី៖ | | | | | | | | |
| - អតិថិជនខាងក្រៅ | ១៦៤.៣២៥.០៣៩ | ៦៦៩.៦២៤.៥៣៤ | ២៣.៥២៧.១០៩ | ៩៥.៨៧២.៩៦៩ | - | - | ១៨៧.៨៥២.១៤៨ | ៧៦៥.៤៩៧.៥០៣ |
| - ភាគីពាក់ព័ន្ធ | ២០.១៤៤.៣៦៤ | ៨២.០៨៨.២៨៣ | ១០.៨៥២.៨៧៨ | ៤៤.២២៥.៤៧៨ | (៤.៥៣៦.៤៩១) | (១៨.៤៨៦.២០១) | ២៦.៤៦០.៧៥១ | ១០៧.៨២៧.៥៦០ |
| | ១៨៤.៤៦៩.៤០៣ | ៧៥១.៧១២.៨១៧ | ៣៤.៣៧៩.៩៨៧ | ១៤០.០៩៨.៤៤៧ | (៤.៥៣៦.៤៩១) | (១៨.៤៨៦.២០១) | ២១៤.៣១២.៨៩៩ | ៨៧៣.៣២៥.០៦៣ |
| **ចំណេញតាមផ្នែក*** | ១៦.៦៩៤.០៦០ | ៦៨.០២៨.២៩៥ | ៦១០.៤៩៦ | ២.៤៨៧.៧៧១ | - | - | ១៧.៣០៤.៥៥៦ | ៧០.៥១៦.០៦៦ |

## ១៦. ព័ត៌មានតាមផ្នែក (ត)

តារាងខាងក្រោមបង្ហាញពីព័ត៌មានតាមផ្នែក សម្រាប់ផ្នែកដែលអាចរាយការណ៍បានសម្រាប់រយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ និងឆ្នាំ២០២៣៖ (ត)

| | ក្រុមហ៊ុន ហ្វដ | | ប្រតិបត្តិការផ្សេងៗ | | ការលុបបំបាត់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **មិនបានធ្វើសវនកម្ម** | | | | | | | | |
| **រយៈពេល ៣ខែ បញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣** | | | | | | | | |
| ចំណូលតាមផ្នែកសរុប | ២៤៩.៦៣៥.១៧៧ | ១.០២២.០០៦.៤១៥ | ២៧.៣៥១.១២៩ | ១១១.៩៧៥.៥២២ | - | - | ២៧៦.៩៨៦.៣០៦ | ១.១៣៣.៩៨១.៩៣៧ |
| ចំណូលតាមផ្នែកអន្តរ | - | - | - | - | (៤.២១៣.៧៨៧) | (១៧.២៥១.២៤៤) | (៤.២១៣.៧៨៧) | (១៧.២៥១.២៤៤) |
| | ២៤៩.៦៣៥.១៧៧ | ១.០២២.០០៦.៤១៥ | ២៧.៣៥១.១២៩ | ១១១.៩៧៥.៥២២ | (៤.២១៣.៧៨៧) | (១៧.២៥១.២៤៤) | ២៧២.៧៧២.៥១៩ | ១.១១៦.៧៣០.៦៩៣ |
| ចំណូលពី៖ | | | | | | | | |
| - អតិថិជនខាងក្រៅ | ២២៨.៨០៩.០៣៥ | ៩៣៦.៧៤៤.១៩០ | ២២.៨១០.៥៣៦ | ៩៣.៣៨៦.៣៣៤ | - | - | ២៥១.៦១៩.៥៧១ | ១.០៣០.១៣០.៥២៤ |
| - ភាគីពាក់ព័ន្ធ | ២០.៨២៦.១៤២ | ៨៥.២៦២.២២៥ | ៤.៥៤០.៥៩៣ | ១៨.៥៨៩.១៨៨ | (៤.២១៣.៧៨៧) | (១៧.២៥១.២៤៤) | ២១.១៥២.៩៤៨ | ៨៦.៦០០.១៦៩ |
| | ២៤៩.៦៣៥.១៧៧ | ១.០២២.០០៦.៤១៥ | ២៧.៣៥១.១២៩ | ១១១.៩៧៥.៥២២ | (៤.២១៣.៧៨៧) | (១៧.២៥១.២៤៤) | ២៧២.៧៧២.៥១៩ | ១.១១៦.៧៣០.៦៩៣ |
| **ចំណេញតាមផ្នែក*** | ៣៥.០៣៩.០៥១ | ១៤៣.៤៤៩.៨៧៥ | ១.២៨១.៣៦៧ | ៥.២៤៥.៩១៧ | - | - | ៣៦.៣២០.៤១៨ | ១៤៨.៦៩៥.៧៩២ |

## ១៦. ព័ត៌មានតាមផ្នែក (ត)

តារាងខាងក្រោមបង្ហាញពីព័ត៌មានតាមផ្នែក សម្រាប់ផ្នែកដែលអាចរាយការណ៍បានសម្រាប់រយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ និង ២០២៣៖ (ត)

| | ក្រុមហ៊ុន ហ្វដ | | ប្រតិបត្តិការផ្សេងៗ | | ការលុបបំបាត់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **មិនបានធ្វើសវនកម្ម** | | | | | | | | |
| **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤** | | | | | | | | |
| ទ្រព្យសកម្មតាមផ្នែកសរុប | ១៤៣.៣៣២.២៤៣ | ៥៨៩.០៩៥.៥១៩ | ៦៨.០៧៦.៦៩៤ | ២៧៩.៧៩៥.២១២ | - | - | ២១១.៤០៨.៩៣៧ | ៨៦៨.៨៩០.៧៣១ |
| បំណុលតាមផ្នែកសរុប | ៦២.៩៥៩.៤៥៥ | ២៥៨.៧៦៣.៣៦០ | ២៣.១៨៩.១៧៧ | ៩៥.៣០៧.៥១៧ | - | - | ៨៦.១៤៨.៦៣២ | ៣៥៤.០៧០.៨៧៧ |
| **បានធ្វើសវនកម្ម** | | | | | | | | |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | |
| ទ្រព្យសកម្មតាមផ្នែកសរុប | ១៩១.៧៣៤.០៩២ | ៧៨៣.២៣៣.៧៦៦ | ៧៥.៩៥៥.៤៣៣ | ៣១០.២៧៧.៩៤៤ | - | - | ២៦៧.៦៨៩.៥២៥ | ១.០៩៣.៥១១.៧១០ |
| បំណុលតាមផ្នែកសរុប | ១២១.២១១.១២១ | ៤៩៥.១៤៧.៤២៩ | ២២.៣៨៩.៧៩៦ | ៩១.៤៦២.៣១៧ | - | - | ១៤៣.៦០០.៩១៧ | ៥៨៦.៦០៩.៧៤៦ |

## ១៦. ព័ត៌មានតាមផ្នែក (ត)

* ការផ្ទៀងផ្ទាត់ចំណេញតាមផ្នែក ទៅនឹងប្រាក់ចំណេញប្រតិបត្តិការមុនបង់ពន្ធត្រូវបានបង្ហាញដូចខាងក្រោម៖

| | រយៈពេល ៦ខែ បញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ មិនបានធ្វើសវនកម្ម | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ចំណេញតាមផ្នែក** | ១៧.៣០៤.៥៥៦ | ៧០.៥១៦.០៦៦ | ៣៦.៣២០.៤១៨ | ១៤៨.៦៩៥.៧៩២ |
| រំលស់នៃ៖ | | | | |
| - ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (២.០៥០.៦៥០) | (៨.៣៥៦.៣៩៩) | (១.៦៧៣.៦៤១) | (៦.៨៥១.៨៨៦) |
| - សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | (៩៨០.២៣២) | (៣.៩៩៤.៤៤៥) | (៥៨០.៦១៣) | (២.៣៧៧.០៣០) |
| ចំណាយហិរញ្ញប្បទាន | (៣.៣៨៥.៦៦៤) | (១៣.៧៩៦.៥៨១) | (២.៩៤៤.៨៨២) | (១២.០៥៦.៣៤៧) |
| ចំណូលហិរញ្ញប្បទាន | ១៩៩.៩១២ | ៨១៤.៦៤១ | ៥១៩.៨២៩ | ២.១២៨.១៨០ |
| ការកត់ត្រាត្រឡប់មកវិញនៃ ការខាតបង់ឱនភាពតម្លៃ លើគណនីអតិថិជនពាណិជ្ជ | ១.៦៧៣ | ៦.៨១៧ | ៣.៦៨៦ | ១៥.០៩០ |
| ការកត់ត្រាត្រឡប់មកវិញ នូវសំវិធានធនលើការធានា | - | - | ៩៩៨.០០០ | ៤.០៨៥.៨១២ |
| សន្និធិដែលមានចលនាយឺតយ៉ាវ | | | | |
| - សំវិធានធន | (៦២៤.៨០៥) | (២.៥៤៦.០៨០) | (៣០០.០០០) | (១.២២៨.២០០) |
| - ការកត់ត្រាត្រឡប់មកវិញ នៃសំវិធានធន | ២.០០៩.០៨១ | ៨.១៨៧.០០៥ | ១.១៣៦.៨៨៩ | ៤.៦៥៤.៤២៤ |
| - ការលុបចោល | ២៤៤.៧៧៧ | ៩៩៧.៤៦៦ | ២០៨.៥០៣ | ៨៥៣.៦១១ |
| **ចំណេញមុនបង់ពន្ធ** | ១២.៧១៨.៦៤៨ | ៥១.៨២៨.៤៩០ | ៣៣.៦៨៨.១៨៩ | ១៣៧.៩១៩.៤៤៦ |

## ១៧. កិច្ចព្រមព្រៀង

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មិនបានធ្វើសវនកម្ម | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បានធ្វើសវនកម្ម | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប័ណ្ណធនាគារពុំមានការធានាដែល ចេញផ្សាយសម្រាប់អ្នកផ្គត់ផ្គង់ | ៦.០០០.០០០ | ២៤.៦៦០.០០០ | ៦.០០០.០០០ | ២៤.៥១០.០០០ |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦១.៨៧៧ | ២៥៤.៣១៤ | ៧៧៨.៣៩៩ | ៣.១៧៩.៧៦០ |
| ភតិសន្យា | ៨.៨៣៣ | ៣៦.៣០៤ | ៣៥.២៨៤ | ១៤៥.០១៧ |

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

### ១៨. តួលេខប្រៀបធៀប

តួលេខជាក់លាក់មួយចំនួនត្រូវបានចាត់ថ្នាក់ឡើងវិញដើម្បីឱ្យមានភាពសមស្របទៅតាមការបង្ហាញនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។

### ១៩. ការអនុញ្ញាតលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនសម្រាប់ត្រីមាស និងរយៈពេល ៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤។

bakertilly

Baker Tilly (Cambodia) Co., Ltd.
Certified Public Accountants
No. 87, Street 294,
Sangkat Boeung Keng Kang 1,
120102, Khan Boeung Keng Kang,
Phnom Penh, Cambodia

T: +855 23 987 100/
+855 23 987 388

info@bakertilly.com.kh
www.bakertilly.com.kh

យោង៖ REV/0109/0824/R001-0112/KMT

**ជូនចំពោះភាគទុនិកនៃ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក**
**របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល**

## សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ និងព្រមទាំងរបាយការណ៍លទ្ធផលលម្អិតសង្ខេបចន្លោះពេលសម្រាប់ត្រីមាស និងរយៈពេល ៦ខែដែលបានបញ្ចប់ របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេលនិងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេលសម្រាប់រយៈពេល ៦ខែដែលបានបញ្ចប់ និងកំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញត្រឹមត្រូវនូវព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមតាមស្តង់ដារអន្តរជាតិនៃកម្ពុជាលើការត្រួតពិនិត្យ ២៤១០ ស្តីពី*ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុចន្លោះពេលដែលធ្វើឡើងដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់នឹងព័ត៌មានហិរញ្ញវត្ថុ និងបញ្ហាឬចម្ងល់លើគណនេយ្យផ្សេងៗព្រមទាំង ការអនុវត្តនូវការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផលយើងខ្ញុំមិនអាចធ្វើការធានាថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាសំខាន់ៗ ដែលអាចនឹងកំណត់បាន ប្រសិនបើធ្វើសវនកម្ម។ ដូច្នេះយើងខ្ញុំមិនអាចបញ្ចេញមតិយោបល់សវនកម្មនោះទេ។



Baker Tilly (Cambodia) Co., Ltd. trading as Baker Tilly is a member of the global network of Baker Tilly International Ltd., the members of which are separate and independent legal entities.

bakertilly

**សេចក្តីសន្និដ្ឋាន**

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ យើងខ្ញុំកត់សម្គាល់ឃើញថា ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍ យើងខ្ញុំ ដែលធ្វើឱ្យយើងខ្ញុំជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលបានភ្ជាប់មកជាមួយនេះមិនត្រូវបានរៀបចំឡើងឱ្យបានត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់គ្រាដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះឡើយ។

| | |
|---|---|
| **បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក** | **ឌុកញ៉ា Tan Khee Meng** |
| ក្រុមហ៊ុនគណនេយ្យករជំនាញ | គណនេយ្យករជំនាញ |
| រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |

ថ្ងៃទី៖ 28 AUG 2024